# កិច្ចតែងការបង្រៀន

- មុខវិជ្ជា ៖ សិក្សាសង្គម
- ថ្នាក់ទី ៖ ១
- ចំណងជើងមេរៀន ៖ សន្តិសុខតាមផ្លូវសាធារណៈ
- ចំណងជើងរង ៖ ការឆ្លងថ្នល់
- រយៈពេល ៖ ១ម៉ោង
- ដកស្រង់ពី ៖ ស.ស. ទំព័រ ៦០ ស.គ. ទំព័រ ៧៥ បោះពុម្ពឆ្នាំ ២០០៥។

## ១. វត្ថុបំណង

- ចំណេះដឹង៖ សិស្សប្រាប់ពីផ្លូវថ្នល់ដែលមានចរាចរណ៍ហូរហែ និងប្រាប់ពីរបៀបដើរឆ្លងថ្នល់បានត្រឹមត្រូវតាមរយៈការធ្វើសកម្មភាពក្រៅថ្នាក់ និងសំណួរបំផុសរបស់គ្រូ។
- បំណិន ៖ សិស្សកំណត់ច្បាស់អំពីភ្លើងសញ្ញាចរាចរណ៍ និងរបៀបដើរឆ្លងថ្នល់ ដោយមានការប្រុងប្រយ័ត្នជានិច្ច នៅពេលធ្វើដំណើរតាមដងផ្លូវសាធារណៈបានត្រឹមត្រូវតាមរយៈលំហាត់ធ្វើចំណែកថ្នាក់ (ទង្វើល្អ និងទង្វើមិនល្អ) និងការអនុវត្តជាក់ស្តែង ។
- ឥរិយាបថ ៖ សិស្សចូលរួមយ៉ាងសកម្មនៅពេលអនុវត្តសកម្មភាព និងយកចំណេះដឹងដែលទទួលបានទៅប្រើប្រាស់ក្នុងជីវភាពជាក់ស្តែងប្រចាំថ្ងៃ ។

## ២. សម្ភារឧបទេស

- ចំពោះគ្រូ ៖ ផ្ទាំងរូបភាពមនុស្សកំពុងធ្វើដំណើរតាមដងផ្លូវ សៀវភៅសិស្សទំព័រទី៦០ រូបភាពក្នុងចំណុច (គ ) និងប័ណ្ណរូបភាព ប័ណ្ណភ្លើងសញ្ញាចរាចរណ៍ ។
- ចំពោះសិស្ស ៖ សៀវភៅសិក្សាសង្គម ។

## ៣ ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ឱ្យប្រធានថ្នាក់ឡើងរាយការណ៍អំពី អវត្តមាន និងបញ្ជាក់មូលហេតុ ។<br>-ពិនិត្យអនាម័យសំលៀកបំពាក់ សក់ ក្រចកដៃ ពិនិត្យសណ្តាប់ធ្នាប់ ឱ្យសិស្ស អង្គុយតាមកន្លែងដោយស្ងៀមស្ងាត់ ។ | ជំហាន ១<br>-ពិនិត្យអវត្តមាន។<br>-ពិនិត្យអនាម័យ ។<br>-ពិនិត្យសណ្តាប់ធ្នាប់។ | -ប្រធានថ្នាក់ឡើងរាយការណ៍។<br>-ក្រោកឈរ ឱ្យគ្រូពិនិត្យ។<br>-អង្គុយស្ងៀមស្ងាត់ប្រុងស្តាប់គ្រូ។ |
| -នៅពេលដើរតាមផ្លូវ កូនៗត្រូវដើរដូចម្តេច?<br>-ហេតុអ្វីបានជាយើងត្រូវដើរប្រកាន់ស្តាំ ? | ជំហាន ២<br>រំលឹកមេរៀនចាស់<br>-ដើរប្រកាន់ស្តាំជានិច្ចលើចិញ្ចើមថ្នល់។<br>-ដើម្បីជៀសវាងគ្រោះថ្នាក់ដល់ខ្លួនឯង និងអ្នកដទៃ។<br>-ឲ្យស្របតាមការចាកចេញរបស់ | - សិស្សឆ្លើយតាមរយៈមេរៀនដែល បានរៀនរួច។<br>-សិស្សឆ្លើយ។ |

| | | |
|---|---|---|
| -ឱ្យសិស្សរកពាក្យបណ្ដៅ ខ្សែមួយចង្វាយរាយគ្រប់ស្រុក តើជាអ្វី ?<br><br>-បើសិស្សមិនអាចរកឃើញគ្រូត្រូវបំផុស សំណួរ ឱ្យបានពាក្យ ផ្លូវ ឬប្រាប់ដល់សិស្ស<br>-តើផ្លូវសម្រាប់ធ្វើអ្វី ?<br><br>-តើនៅតាមជនបទស្រុកស្រែចំការមានផ្លូវ សម្រាប់ដើរឬទេ? | យានយន្ត។<br><br><u>ទំនាក់ទំនងមេរៀនថ្មី</u><br>-ពាក្យបណ្ដៅ។<br>-ខ្សែមួយចង្វាយរាយគ្រប់ស្រុក (ជាផ្លូវ )<br>-ផ្លូវសម្រាប់ធ្វើដំណើរទៅមក<br><br>-តាមស្រុកស្រែចំការ ក៏មានផ្លូវដែរ | -សិស្សគិតរួច ឆ្លើយតាមការយល់ឃើញរបស់គេ។<br>-សិស្សឆ្លើយតាមរយៈសមត្ថភាព មានស្រាប់។<br><br>- ឆ្លើយបានតាមរយៈការដឹង និង ឃើញជាក់ស្តែង |
| -តើកូនៗ ចេះដើរឆ្លងផ្លូវដែរឬទេ?<br><br>-ថ្ងៃនេះអ្នកគ្រូពិតជាចង់ដឹងអំពីសកម្មភាព របស់កូនៗនៅពេលដែលកូនធ្វើ ដំណើរតាមផ្លូវសាធារណៈ<br><br>-គ្រូចែកសិស្សជា ៥ ក្រុម។<br>-ចែកប័ណ្ណរូបភាពឱ្យសិស្ស ម្នាក់ ១ សន្លឹក ក្នុងនោះមានរូបមនុស្ស កំពុងដើរ រូបមនុស្ស ជិះកង់ រូបមនុស្ស ជិះម៉ូតូ និងរូបមនុស្ស ជិះឡាន ។<br>- ណែនាំសិស្សអំពីរបៀបធ្វើសកម្មភាពនៅ ក្រៅថ្នាក់។<br>-ពន្យល់លើរូបភាពនីមួយៗឱ្យធ្វើត្រាប់ សម្លេង តាមរូបភាពរៀងៗខ្លួន ឧ: នៅពេល ជិះកង់តែង ឮសូរសំឡេងឌីត ង៉តៗ ជាដើម ធ្វើសម្លេងត្រាប់ កុមារម្នាក់ ធ្វើជាប៉ូលីសដើម្បីចាំចាប់អ្នកដែលធ្វើដំណើរ ឆ្លងផ្លូវដោយ មិនមើលឆ្វេង ស្តាំ ឬមិនមើលភ្លើង សញ្ញាពណ៌ក្រហម ។<br>-ដឹកនាំសិស្សសាកល្បងក្នុងថ្នាក់ដើម្បី បង្ហាញ ការសម្តែងផ្ទាល់។ ចាត់ចែងសកម្មភាពក្រៅថ្នាក់ | <u>ជំហាន ៣ មេរៀនថ្មី</u><br><u>ការឆ្លងថ្នល់</u><br>-មើល ឆ្វេង ស្តាំ មុខ ក្រោយ<br><br>សកម្មភាពល្បែង<br><br>-ធ្វើត្រាប់សូរសម្លេងតាមរូបនៅពេលចេញដំណើរ។<br><br>-សាកល្បងការសម្តែងផ្ទាល់។<br><br>សកម្មភាពក្រៅថ្នាក់នេះបង្ហាញអំពីរបៀបធ្វើចរាចនៅលើផ្លូវសាធារណៈជាពិសេសចេះឆ្លង | -សិស្សឆ្លើយបានតាមការដឹងឮពីឪពុកម្តាយនិងអ្នកនៅជុំវិញខ្លួនគេ<br><br>-សិស្សកាន់រូបរៀងៗខ្លួន។<br><br>-ស្តាប់ការណែនាំ។<br><br>-ធ្វើសម្លេងនិងកាយវិការត្រាប់តាម។<br><br>-សិស្សមួយក្រុមតូចសាកល្បងសកម្មភាព។ |

| | | |
|---|---|---|
| -ឱ្យកុមារ ៤ នាក់ឈរត្រង់ចំណុច ផ្លូវបំបែកដើម្បីរងចាំកំណត់សញ្ញា ភ្លើងស្តុប<br>-ណែនាំសិស្ស ៦ នាក់ឱ្យជួយពិនិត្យ មើល។<br>-ក្រុមទី១<br>ធ្វើដំណើរពីទិសខាងលិច។<br>-ក្រុមទី ២<br>ធ្វើដំណើរពីទិសខាងកើត។<br>-ក្រុមទី៣<br>ធ្វើដំណើរពីទិសខាងជើង។<br>-ក្រុមទី៤<br>ធ្វើដំណើរពីទិសខាងត្បូង។<br>-ក្រុមទី៥ ជាអ្នកថ្មើរជើងធ្វើដំណើរ ឆ្លងថ្នល់។ | ថ្នល់ និងមើលភ្លើងសញ្ញា ចរាចរបានត្រឹមត្រូវជៀសវាង គ្រោះថ្នាក់ជាយថាហេតុ។ | -សិស្ស ៤ នាក់ឈរចាំលើក ភ្លើងសញ្ញា នៅចំណុចភ្លើងស្តុប (ផ្លូវបំបែកជា៤)។<br><br>-អនុវត្ត។ |
| -នាំសិស្សចូលថ្នាក់<br>ដើម្បីធ្វើសំយោគ។ | | -សិស្សទាំងអស់នាំគ្នាចូល ថ្នាក់។ |
| -ឱ្យសិស្សបើកសៀវភៅសិក្សា សង្គមត្រង់ទំព័រ ៦០ នៅចំណុច **គ** រួចសួរ។ | -បើកសៀវភៅសិក្សាសង្គម ទំព័រ ៦០ នៅចំណុច **គ** | -សិស្សបើកសៀវភៅរួចសង្កេត មើលរូបភាពក្នុងសៀវភៅសិស្ស |
| -តើកូនសង្កេតឃើញមាន សកម្មភាព អ្វីខ្លះនៅខាងក្រៅថ្នាក់ ?<br><br>-ហេតុអ្វីបានជាមនុស្សខ្លះឈប់នៅ ត្រង់ ចំណុចភ្លើងស្តុប? | -មានកុមារដើរលើចិញ្ចើមថ្នល់។<br>-មានកុមារម្នាក់ ជិះកង់ឆ្លងថ្នល់។<br>-មានឡាន ម៉ូតូធ្វើចរាចរទៅមក។<br>-មានមនុស្សម្នាក់កំពុងឈប់នៅ ត្រង់ភ្លើងស្តុបព្រោះគាត់ឃើញ ភ្លើងសញ្ញាពណ៌ ក្រហមដែល ជាសញ្ញាឱ្យឈប់។ | -សិស្សឆ្លើយតាមការសង្កេត និងការយល់ដឹងពេលលេង ល្បែង។<br>-សិស្សរៀបរាប់សកម្មភាពក្រៅ ថ្នាក់ ឡើងវិញ។<br><br>-សិស្សឆ្លើយ។ |
| -បង្ហាញរូបកុមារម្នាក់កំពុងរត់ឆ្លង ថ្នល់ ដោយមិនមើលឆ្វេង ស្តាំ រួចសួរ:<br>-តើកុមារនេះកំពុងធ្វើអ្វី ?<br><br>-តើកូនៗគួរយកតម្រាប់តាមកុមារ នេះ ឬទេ?<br>-បង្ហាញរូប។<br>-ដើម្បីជៀសវាងគ្រោះថ្នាក់នៅពេល ធ្វើ ដំណើរតាមដងផ្លូវ<br>តើកូនៗត្រូវធ្វើដូចម្តេច? | -កំពុងរត់ឆ្លងកាត់ថ្នល់ដោយមិន មើល ឆ្វេងស្តាំ<br>-មិនគួរយកតម្រាប់តាមព្រោះជា ទង្វើ មិនល្អ នាំឱ្យគ្រោះថ្នាក់<br><br>-ត្រូវធ្វើដំណើរប្រកាន់ស្តាំ និងដើរឆ្លង ដោយមានបម្រុង ប្រយ័ត្នជានិច្ច មិនប្រឡែងគ្នានៅ ពេលកំពុងឆ្លងថ្នល់ ត្រូវដើរឆ្លងកាត់ គំនូសសអង្កត់បណ្តោយថ្នល់ត្រង់។ | -សិស្សសង្កេតរូបភាព។<br><br>-សិស្សឆ្លើយ។<br>-សិស្សឆ្លើយ។<br>-សិស្សសង្កេតរូបភាព។<br>-សិស្សឆ្លើយ។ |

<table>
<tr>
<td>-តើឆ្លងកាត់សកម្មភាពទាំងប៉ុន្មាន ដែលកូន បានឃើញ និងបាន អនុវត្តខាងលើនេះ។<br>តើកូនអាចប្រាប់បានទេថាយើងបានរៀនអំពីអ្វី?<br><br>-ពន្យល់ពាក្យបម្រុងប្រយ័ត្នដល់សិស្ស។<br><br>-សរសេរចំណងជើងមេរៀន លើក្តារខៀន។</td>
<td>ពេលឆ្លងថ្នល់ត្រូវមើលភ្លើងសញ្ញាចរាចរឱ្យបានច្បាស់លាស់ ។<br><br>-ពាក្យថាបម្រុងប្រយ័ត្នមានន័យថា៖<br>ការតាំងចិត្តប្រុងប្រយ័ត្នដោយមិនធ្វេសប្រហែស។<br><br>បង្ហាញចំណងជើងមេរៀន</td>
<td>-សិស្សឆ្លើយរៀនអំពីរបៀបដើរឆ្លង ថ្នល់។<br><br>-សិស្សស្តាប់។<br><br>-សិស្សមើល និងអានតាមគ្រូ។</td>
</tr>
<tr>
<td>-លំហាត់ធ្វើចំណែកថ្នាក់។<br>-ចែកប័ណ្ណរូបភាពទៅសិស្សម្នាក់១។<br>-ឱ្យសិស្សឡើងយករូបភាពទៅបិទលើ ក្តារខៀន (ទង្វើល្អ ឬមិនល្អ)។<br>-ដំបូងឱ្យសិស្សកែលម្អ។<br>-គ្រូវាយតម្លៃ។</td>
<td><u>ជំហាន ៤</u><br>រើសរូបទៅបិទ<br><table><tr><th><u>ទង្វើល្អ</u></th><th><u>ទង្វើមិនល្អ</u></th></tr><tr><td></td><td></td></tr></table></td>
<td>-យករូបភាពទៅបិទម្នាក់ម្តងៗ។<br><br>-សិស្សឡើងកែកំហុសរបស់មិត្តភក្តិ។<br>-សិស្សទាំងអស់សង្កេត និងស្តាប់។</td>
</tr>
<tr>
<td>-នៅពេលកូនធ្វើដំណើរទៅណាមកណា តាមផ្លូវសាធារណៈកូនៗត្រូវតែប្រុង ប្រយ័ត្ន មុនឆ្លងផ្លូវត្រូវមើលភ្លើងសញ្ញាចរាចរណ៍មិនត្រូវ រត់ឆ្លងកាត់ផ្លូវ ឬប្រឡែងគ្នាតាមផ្លូវឡើយ ។</td>
<td><u>ជំហាន ៥</u> បណ្តាំផ្ញើ<br>-ណែនាំសិស្ស។</td>
<td>-ស្តាប់ អនុវត្តតាមការណែនាំរបស់គ្រូ។</td>
</tr>
</table>